# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ២០២១

## បច្ចុប្បន្នភាពស្តីអំពីគម្រោងទិដ្ឋាការកសិកម្មអូស្ត្រាលី

កាលពីថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០២១ រដ្ឋាភិបាលអូស្ត្រាលីបានប្រកាសបង្កើត គម្រោងទិដ្ឋាការកសិកម្មអូស្ត្រាលីថ្មី។ យើងនឹងធ្វើការចរចាជាមួយដៃគូទ្វេភាគី អំពីការរៀបចំនានាសម្រាប់ទិដ្ឋាការនេះ ដោយចាប់ផ្តើមពីបណ្តាប្រទេសមួយចំនួន មុននឹងពង្រីកទៅបណ្តាប្រទេសជាច្រើន ទៅថ្ងៃមុខ។

បច្ចុប្បន្ននេះ មិនទាន់មានការរៀបចំទិដ្ឋាការកសិកម្មទ្វេភាគី រវាងអូស្ត្រាលីនិងកម្ពុជា នៅឡើយទេ។ ប្រជាជនកម្ពុជាគួរប្រយ័ត្នចំពោះក្រុមហ៊ុនណាដែលអះអាងថា គេអាចរៀបចំទិដ្ឋាការកសិកម្មសម្រាប់អូស្ត្រាលីបាន នាបច្ចុប្បន្ននេះ។

ព័ត៌មានលំអិតអំពីរបៀបដាក់ពាក្យសុំ និងតម្រូវការដើម្បីទទួលបានទិដ្ឋាការ នឹងធ្វើឡើងតាម រយៈដំណើរការកម្មវិធី ដោយមានការពិគ្រោះយោបល់ជាមួយវិស័យកសិកម្មអូស្ត្រាលី។ ក្រសួងកិច្ចការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី ជាអ្នកគ្រប់គ្រងលើទិដ្ឋាការនេះ។ ក្រសួងមហាផ្ទៃ និងក្រសួងកសិកម្ម ទឹក និងបរិស្ថាន នឹងផ្តល់ការគាំទ្រផ្នែកប្រតិបត្តិការ ដើម្បីធានាសុចរិតភាពទិដ្ឋាការ ព្រមទាំងដើម្បីបំពេញតម្រូវការវិស័យកសិកម្ម និងវិស័យឧស្សាហកម្មបឋម។

ស្តង់ដារអប្បបរមាដើម្បីការពារកម្មករ ពីការកេងប្រវ័ញ្ច ជាការសំខាន់ ហើយនឹងត្រូវយកគំរូតាមកម្មវិធីចល័តពលកម្មប៉ាស៊ីហ្វិក ដែលទទួលបានជោគជ័យរបស់អូស្ត្រាលី។ នៅពេលការរៀបចំទិដ្ឋាការត្រូវបានបញ្ចប់ នឹងមានច្បាប់តឹងរ៉ឹងដើម្បីការពារកម្មករ។ រដ្ឋាភិបាលប្តេជ្ញាធានាថា កម្មករទាំងអស់មានឱកាសចូលរួមចំណែកជាវិជ្ជមាន ដល់សេដ្ឋកិច្ចអូស្ត្រាលី ដោយមិនមានអារម្មណ៍ភ័យខ្លាចពីការកេងប្រវ័ញ្ច។

ពលករទាំងអស់នៅក្នុងប្រទេសអូស្ត្រាលី មានសិទ្ធិ និងការការពារដូចគ្នា នៅកន្លែងធ្វើការ ដោយមិនគិតពីសញ្ជាតិ ឬស្ថានភាពទិដ្ឋាការឡើយ។ សិទ្ធិនិងការការពារទាំងនេះ នឹងបន្តអនុវត្តចំពោះកម្មករដែលមកកាន់ប្រទេសអូស្ត្រាលី ក្រោមទិដ្ឋាការកសិកម្មអូស្ត្រាលី។

**ទំនាក់ទំនងព័ត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au